ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៧៨ អយក.សសរ

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតក្រុមពិគ្រោះយោបល់លើការតាក់តែង លិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/០៩៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសេចក្ដីសម្រេចលេខ ២៣ អយក.សសរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២ ស្ដីពីការបង្កើតក្រុមការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមពិគ្រោះយោបល់លើការតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំ ដែលស្ថិតនៅក្រោមក្រុមការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌របស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីជួយក្រុមការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌របស់ក្រសួងអប់រំ យុវជន និងកីឡា លើការកសាងលិខិតបទដ្ឋានគតិយុត្ត។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ ២.-**

សមាសភាពនៃក្រុមពិគ្រោះយោបល់លើការតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំ មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ឯកឧត្តម | **ទូច** | **ទិសាលសុខ** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ឯកឧត្តម | **សៀង** | **សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ឯកឧត្តម | **អ៊ុំ** | **រម្យណី** | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ឯកឧត្តម | **ហោ** | **ប៉េង** | សាកលវិទ្យាធិការនៃ ស.ជ.គ. | សមាជិក |
| ឯកឧត្តម | **លុយ** | **ចណ្ណា** | សាកលវិទ្យាធិការនៃ ស.ភ.វ.ន.ស. | សមាជិក |
| ឯកឧត្តម | **ជេត** | **ជាលី** | សាកលវិទ្យាធិការនៃ ស.ភ.ភ.ព. | សមាជិក |
| លោក | **ស៊ិន** | **សេខហុត** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិកអចិន្ត្រៃយ៍ |
| លោក | **ហាប់** | **ផល្លី** | នាយករងថ្នាក់ក្រោយឧត្តមនៃស.ភ.វ.ន.ស. | សមាជិក |
| លោក | **អ៊ុន** | **ឈាង** | អនុប្រធាននាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| លោក | **ឌី** | **សំស៊ីដេត** | បុគ្គលិកអប់រំនៃ ស.ភ.ភ.ព. | សមាជិក |
| លោក | **ម៉ូច** | **ទី** | អនុប្រធានការិយាល័យនីតិកម្ម | សមាជិកអចិន្ត្រៃយ៍ |

**ប្រការ ៣.-**

ក្រុមពិគ្រោះយោបល់លើការតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំនេះ មានតួនាទីនិងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ចូលរួមប្រជុំពិភាក្សាជាមួយក្រុមការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌របស់ក្រសួងអប់រំ យុវជន និងកីឡាលើការកសាងលិខិតបទដ្ឋានគតិយុត្តនិងគោលនយោបាយពាក់ព័ន្ធនឹងវិស័យអប់រំតាមការអញ្ជើញ
- លើកអនុសាសន៍ព្រមទាំងវិធានផ្នែកបច្ចេកទេស ផ្នែកគតិយុត្ត និងផលប៉ះពាល់ដល់ក្រុមការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌របស់ក្រសួងអប់រំ យុវជន និងកីឡាលើការកសាងលិខិតបទដ្ឋានគតិយុត្តនិងគោលនយោបាយពាក់ព័ន្ធនឹងវិស័យអប់រំ។

**ប្រការ ៤.-**

ក្រុមពិគ្រោះយោបល់លើការតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំមានលេខាធិការដ្ឋាននៃក្រុមការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌របស់ក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ។

**ប្រការ ៥.-**

សេចក្តីសម្រេចលេខ២៦ អយក.សសរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការបង្កើតក្រុមពិគ្រោះយោបល់លើការតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យអប់រំត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១៣

**កន្លែងទទួល៖**

- ក្រុមការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ របស់ក្រសួងអប់រំ យុវជន និងកីឡា "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្ត នា.នីតិកម្ម

**បណ្ឌិត ហង់ ជួន ណារ៉ុន**